# ទស្សនទាន
# សិក្ខាសាលាស្តីពី «ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយខ្សែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល»

កាលបរិច្ឆេទ៖ ថ្ងៃព្រហស្បតិ៍ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤
ម៉ោង៖ ៨:០០ ព្រឹក ដល់ម៉ោង ១១:៣០ ថ្ងៃត្រង់
**ទីកន្លែង៖ សណ្ឋាគារ រ៉ាហ្វ៊ែល ឡឺរ៉ូយ៉ាល់ (Raffles Hotel Le Royal)**

## ១. សាវតា

ការពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធចំពោះនីតិបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមនីតិរូបនៃរបបសារពើពន្ធ ដោយរួមបញ្ចូលទាំងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានជះឥទ្ធិពលលើបរិកាសអំណោយផលរបស់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាផ្សេងទៀត គឺការបើកសហគ្រាសសង្គម និងការចុះបញ្ជីសកម្មភាពអាជីវកម្មដោយខ្សែក។

យោងតាមមាត្រា៩ (ចំណុចទី៣) នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ២០២៣ បានចែងថា "ក្នុងករណីអង្គការ ឬសមាគម មានសកម្មភាពខាងពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬអាជីវកម្មផ្សេងទៀតដែលមិនទាក់ទិនដល់គោលដៅ ឬមុខងារជាមូលដ្ឋាននៃការលើកលែងពន្ធរបស់ខ្លួន ប្រាក់ចំណូលដែលបានមកពីសកម្មភាពមិនទាក់ទិនទាំងនោះត្រូវជាប់ពន្ធតាមមាត្រា ២០ នៃច្បាប់នេះ"។ លើសពីនេះ ច្បាប់ក៏បានតម្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ ធ្វើការចុះបញ្ជីអាជីវកម្មដោយខ្សែក ផងដែរ។

ការវិវត្តន៍ខាងលើនេះ បានក្លាយទៅបញ្ហាប្រឈមមួយដ៏សំខាន់របស់អង្គការសង្គមស៊ីវិលនៅកម្ពុជាជាទូទៅ។ ជាពិសេស សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងបង្កើតសហគ្រាសសង្គម (Social Enterprise) ដើម្បីកៀរគរធនធានក្នុងស្រុកបន្ថែមទៀតដើម្បីគាំទ្រដល់បេសកកម្ម និងសកម្មភាពមនុស្សធម៌ និងការអភិវឌ្ឍន៍សង្គមរបស់ខ្លួន ជាពិសេស គឺដើម្បីធានានូវនិរន្តរភាពរបស់ស្ថាប័ន។

បញ្ហាប្រឈមផ្សេងទៀតនោះ គឺកង្វះខាតព័ត៌មាន ការណែនាំ និងបទពិសោធន៍ជាក់ស្តែងពាក់ព័ន្ធទៅនឹងចុះបញ្ជីអាជីវកម្មដោយខ្សែក និងការប្រកាសពន្ធផ្សេងៗដែលការអនុវត្តនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងនីតិបុគ្គលឯកជនដែលស្វែងរកប្រាក់ចំណេញសុទ្ធសាទ ស្របពេលដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើទំនើបកម្មទាំងក្របខណ្ឌច្បាប់ និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យពន្ធដារ។ តាមរយៈនៃការអនុវត្តន៍កន្លងមក សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងចុះបញ្ជីអាជីវកម្មដាច់ដោយខ្សែក ត្រូវបានតម្រូវឱ្យបំពេញកាតព្វកិច្ចផ្សេងៗជាច្រើនជាមួយ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងនិយ័តករគណនេយ្យ និងសវនកម្ម ជាដើម។

ឆ្លើយតបទៅនឹងការវិវត្តន៍និងបញ្ហាខាងលើ និងដើម្បីរួមចំណែកធ្វើឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចរៀនសូត្រ និងឈ្វេងយល់បានកាន់តែប្រសើរអំពីនីតិវិធី និងដំណើរការនៃការចុះបញ្ជីអាជីវកម្មដោយខ្សែក និងការប្រកាសពន្ធស្របតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងពាក់ព័ន្ធនឹងវិស័យពន្ធដារ ព្រមទាំងផ្តល់ឱកាសឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានលើកឡើងនូវផលវិបាក បញ្ហាប្រឈម និងសំណូមពរ

ផ្សេងៗជូនក្រសួងដែលទទួលបន្ទុកការងារខាងលើនេះ។ អង្គការ គ.ស.ក នឹងសម្របសម្រួលឱ្យមានសិក្ខាសាលាស្តីពី «ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល»។ ដើម្បីឱ្យសិក្ខាសាលានេះ ប្រព្រឹត្តទៅបានល្អ និងអាចឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុក អង្គការ គ.ស.ក នឹងស្នើសុំកិច្ចសហការជាពីអគ្គនាយកដ្ឋានពន្ធដារ និងក្រសួងពាក់ព័ន្ធផ្សេងទៀត ចូលរួមជាវាគ្មិនគន្លឹះ និងដោយមានការចូលរួមពីតំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលជាសមាជិករបស់ គ.ស.ក ព្រមទាំងសមាគម និងអង្គការដៃគូផ្សេងទៀត។

## ២. គោលបំណង

- ដើម្បីលើកកម្ពស់ការយល់ដឹងដល់អ្នកចូលរួមអំពីការអនុវត្តកាតព្វកិច្ចសារពើពន្ធ នីតិវិធី និងដំណើរការនៃការចុះបញ្ជីអាជីវកម្មដោយឡែកសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ។
- បង្កើតឱ្យមានកិច្ចសន្ទនារវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាមួយតំណាងអគ្គនាយកដ្ឋានពន្ធដារ ក្រសួងស្ថាប័នពាក់ព័ន្ធ និងផ្តល់ឱកាសឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លើកឡើងនូវសំណូមពរ បញ្ហាប្រឈមរបស់ពួកគេក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ និងការចុះបញ្ជីអាជីវកម្មដាច់ដោយឡែកនាពេលកន្លងមក។

## ៣. អ្នកចូលរួម

សិក្ខាសាលាខាងលើនេះ រំពឹងថានឹងមានអ្នកអញ្ជើញចូលរួមចំនួនប្រមាណ ១៥០-២០០ នាក់ ដែលជាតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសជាសមាជិកនៃអង្គការ គ.ស.ក សមាគម អង្គការដៃគូ និងភាគីពាក់ព័ន្ធដទៃផ្សេងទៀត ។

## ៤.របៀបវារៈ

| ពេលវេលា | សកម្មភាព | អ្នកសម្របសម្រួល/ឧទ្ទេសនាម |
|---|---|---|
| ៧:៤៥–៨:១៥ | ចុះឈ្មោះអ្នកចូលរួម | ក្រុមការងារអង្គការ គ.ស.ក |
| ៨:១៥–៨:៣០ | ប្រកាសហេតុ និងគោរពភ្លេងជាតិ<br>ការណែនាំ និងគោលបំណងសិក្ខាសាលា | លោកស្រី **ប្រាក់ កែវគង្គា**<br>អ្នកឯកទេសផ្នែកច្បាប់ អង្គការ គ.ស.ក |
| ៨:៣០–៨:៥០ | មតិស្វាគមន៍ | លោកស្រី **ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិនៃអង្គការ គ.ស.ក |
| ៨:៥០–០៩:១០ | សុន្ទរកថាបើកសិក្ខាសាលា | តំណាងអគ្គនាយកដ្ឋានពន្ធដារ<br>(បញ្ជាក់ជូនតាមក្រោយ) |
| ៩:១០–៩:៣០ | ថតរូបជុំគ្នា និងសម្រាកពិសារអាហារសម្រន់ | |
| ៩:៣០–១០:០០ | បទបង្ហាញស្តីពី "**ការចុះបញ្ជីសកម្មភាពអាជីវកម្មដោយឡែករបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**" | តំណាងអគ្គនាយកដ្ឋានពន្ធដារ<br>(បញ្ជាក់ជូនតាមក្រោយ) |



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street. 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

| | | |
|---|---|---|
| | • ការអនុវត្ត និងលក្ខខណ្ឌផ្សេងៗក្នុងការចុះបញ្ជី<br>• លក្ខខណ្ឌអនុគ្រោះ និងការលើកទឹកចិត្តពន្ធដារ | |
| ១០:០០–១១:៣០ | **កិច្ចពិភាក្សា ៖**<br>• តំណាងអគ្គនាយកដ្ឋានពន្ធដារ<br>• តំណាងនិយ័តករគណនេយ្យ និងសវនកម្ម<br>- លោក **យាន ផល្លា** ប្រធានការិយាល័យអនុលោមទី៣<br>- លោកស្រី **ទី មួយហួយ** មន្ត្រីជំនាញការិយាល័យអនុលោមទី៣<br>- កញ្ញា **ចៅ ប៉ូលីតា** មន្ត្រីជំនាញការិយាល័យអនុលោមទី១ | សម្របសម្រួលដោយៈ<br>លោកស្រី **លុយ ធារី**<br>ប្រធានកម្មវិធីអង្គការ គ.ស.ក |

***កំណត់សម្គាល់៖**

- អ្នករៀបចំកម្មវិធីសូមថតរូប វីដេអូ ឬសម្លេងសម្រាប់ការអប់រំផ្សព្វផ្សាយ និងកត់ត្រាកំណត់ហេតុ និង សូមរក្សាសិទ្ធិក្នុងការកែសម្រួលរបៀបវារៈខាងលើតាមការចាំបាច់។
- សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងអ្នករៀបចំកម្មវិធី។